**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ការដោះស្រាយវិវាទការងារនៅក្រុមហ៊ុនណាហ្គាវើលដ៍

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់កម្មករនិយោជិតនៃក្រុមហ៊ុនណាហ្គាវើលដ៍ និងសាធារណជនឱ្យបានជ្រាបថា នាពេលកន្លងមកនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានខិតខំនិងព្យាយាមធ្វើការដោះស្រាយវិវាទការងារនៃក្រុមហ៊ុនណាហ្គាវើលដ៍ ស្របតាមនីតិវិធីច្បាប់ជាធរមាន ដោយចាប់ផ្តើមពីយន្តការផ្សះផ្សាដោយអធិការការងារជាបន្តបន្ទាប់រហូតដល់យន្តការក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ករណីវិវាទនេះក៏ត្រូវបានសម្របសម្រួលដោះស្រាយដោយមានការចូលរួមពីរដ្ឋបាលរាជធានីភ្នំពេញផងដែរ ប៉ុន្តែគួរឱ្យសោកស្តាយដោយសារមានចំណុចមួយចំនួនត្រូវបានភាគីបានឯកភាពគ្នា និងចំណុចមួយចំនួននៅមិនទាន់មានការឯកភាពគ្នា។

ដូចនេះ ក្នុងអំឡុងពេលនៃការទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ជាពិសេសមេរោគកូវីដ-១៩ បំប្លែងខ្លួនថ្មីប្រភេទ "អូមីក្រុង" ក្រសួងសូមអំពាវនាវដល់បងប្អូនកម្មករនិយោជិតដែលបានធ្វើកូដកម្ម ដូចខាងក្រោម៖

១- ត្រូវបន្តធ្វើការពិភាក្សាដោះស្រាយដោយសន្តិវិធី និងរក្សាភាពស្ងៀមស្ងាត់ ស្របតាមនីតិវិធីច្បាប់ ក្រោមការសម្របសម្រួលដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋបាលរាជធានីភ្នំពេញ។

២- ត្រូវផ្អាកការធ្វើកូដកម្ម បាតុកម្ម ដើម្បីចូលរួមរក្សាការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងចូលរួមទប់ស្កាត់ការឆ្លងរីករាលដាលជំងឺកូវីដ-១៩។

៣- ក្រសួង និងអាជ្ញាធរពាក់ព័ន្ធ ជាពិសេសរដ្ឋបាលរាជធានីភ្នំពេញនឹងបន្តធ្វើការដោះស្រាយ យោងតាមនីតិវិធីច្បាប់ជាធរមាន និងផ្អែកតាមសមភាព សមធម៌ ដើម្បីធានាថា បងប្អូនកម្មករនិយោជិតដែលកំពុងតវ៉ាទទួលបាននូវដំណោះស្រាយមួយសមស្រប និងអាចទទួលយកបានទាំងអស់គ្នា។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមបងប្អូនកម្មករនិយោជិតនៃក្រុមហ៊ុនណាហ្គាវើលដ៍ និងសាធារណជនមេត្តាជ្រាបជាព័ត៌មាននិងរក្សាភាពនឹងនរក្នុងចិត្ត ចៀសវាងចាញ់បោកជនខិលខូចមួយចំនួនដែលមានបំណងញុះញង់បង្កអស្ថិរភាពដល់ក្រុមហ៊ុន និងសណ្តាប់ធ្នាប់សាធារណៈ ដែលអាចបង្កផលប៉ះពាល់ដល់ការងាររបស់បងប្អូនកម្មករនិយោជិតដទៃទៀតដែលកំពុងបំពេញការងារនិងទទួលបានប្រាក់ឈ្នួលពីក្រុមហ៊ុនណាហ្គាវើលដ៍។

ថ្ងៃសៅរ៍ ១៤កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២១